**មាត្រា ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

※※※

**អនុក្រឹត្យលេខ ២១ អនក្រ.បក**

**ស្តីពី**

**ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តកំពង់ចាម ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ**

※※※

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងនៅទឹកសាប ក្នុងខេត្តកំពង់ចាម ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទលេខ ៤ ៦ ៧ ១១ក និងលេខ ១១គ ព្រះទាំងឡូត៍ឆ្នេរខ្សាច់លេខ ១. ៣. ៦. ៨. ៩. ១០. ១៣. ១៧. ១៨. ១៩. ២០ និងលេខ ២១ ចាប់ពីរដូវនេសាទឆ្នាំ ២០០០-២០០១ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តកំពង់ចាម និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ។ ចំពោះឡូត៍នេសាទលេខ ១០ ដែលត្រូវកាត់ ៦.៩៥៦ ហិកតា ចេញពីនាទីឡូត៍នេសាទ ក្នុងនោះរក្សាទុកអន្លង់ត្រីមេពូជ ចាប់ពីស្ពានស្ទឹងគរគី រហូតដល់បឹងជីធាងដែលមានផ្ទៃក្រឡា ១៤២ ហិកតា ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកំពង់ចាម ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៣.៤៥០ | ២.៤៣៦ | ១.០១៤ | ៧០.៦០ | |
| ២ | ១០.៩៩២ | ៦.៧៥៣ | ៤.២៣៩ | ៦១.៤៣ | |

| | | | | | |
|---|---|---|---|---|---|
| ៣ | ៣.២៨៤ | ១.៨៥៩ | ១.៤២៥ | ៥៦.៦០ | |
| ៤ | ២.២៨៤ | ២.២៨៤ | 0 | ១០០ | លុបចេញ |
| ៥ | ៤.២០៧ | ២.៨១០ | ១.៣៩៧ | ៦៦.៧៩ | |
| ៦ | ៣.៦៧៤ | ៣.៦៧៤ | 0 | ១០០ | លុបចេញ |
| ៧ | ៣.៨៩៣ | ៣.៨៩៣ | 0 | ១០០ | លុបចេញ |
| ៨ | ៣.៣៣៣ | ១.៧៨៩ | ១.៥៤៤ | ៣៥.៦៧ | |
| ៩ | ៧.៨៣៥ | ៤.៨០១ | ៣.០៣៤ | ៦១.២៧ | |
| ១០ | ១៨.៤៣៤ | ៦.៩៥៦ | ១១.៤៧៨ | ៣៧.៧៣ | រក្សាទុក ១៤២ហ.ត |
| ១១ក | ២.១៩៤ | ២.១៩៤ | 0 | ១០០ | លុបចេញ |
| ១១គ | ៥៦២ | ៥៦២ | 0 | ១០០ | លុបចេញ |
| **សរុប ក ១២** | ៦៤.១៤២ | ៤០.០១១ | ២៤.១៣១ | ៦២.៣៨ | |
| ឡូត៍ឆ្នេរខ្សាច់ | | | | | |
| ១ | ២៨ | ២៨ | 0 | ១០០ | លុបចេញ |
| ៣ | ៥៦ | ៥៦ | 0 | ១០០ | លុបចេញ |
| ៦ | ៤២ | ៤២ | 0 | ១០០ | លុបចេញ |
| ៨ | ១៣១ | ១៣១ | 0 | ១០០ | លុបចេញ |
| ៩ | ២០ | ២០ | 0 | ១០០ | លុបចេញ |
| ១០ | ៣៧ | ៣៧ | 0 | ១០០ | លុបចេញ |
| ១៣ | ៥៩ | ៥៩ | 0 | ១០០ | លុបចេញ |
| ១៧ | ៨៣ | ៨៣ | 0 | ១០០ | លុបចេញ |
| ១៨ | ១១២ | ១១២ | 0 | ១០០ | លុបចេញ |
| ១៩ | ៨៣ | ៨៣ | 0 | ១០០ | លុបចេញ |
| ២០ | ១០២ | ១០២ | 0 | ១០០ | លុបចេញ |
| ២១ | ១១០ | ១១០ | 0 | ១០០ | លុបចេញ |
| **សរុប ខ ១២** | **៨៦៣** | **៨៦៣** | **0** | **១០០** | |
| **សរុប កខ ២៤** | **៦៥.០០៥** | **៤០.៨៧៤** | **២៤.១៣១** | **៦២.៨៨** | |

**មាត្រា ២.-**

ដែននេសាទដែលបានលុបចេញ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២២ អនក្រ.បក

## ស្តីពី

## ការលុបដែននេសាទ ក្នុងនាទីឡូត៍នេសាទ នៃទន្លេជាយត្រី រាជធានីភ្នំពេញ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា